សង្គតថានៅថ្ងៃទី២៨ មិនា ២០១៥
របស់លោកស្រី យីម ណុលស៊ីណា ប្រធានមជ្ឈមណ្ឌលខេមរា
មជ្ឈមណ្ឌលប្រវត្តិសាស្ត្រ និងអារ្យធម៌ខ្មែរ
ក្នុងពិធីរំលឹកខួបទី៤០ដល់ជនរងគ្រោះដោយរបបប្រល័យពូជសាសន៍ខ្មែរក្រហម
និងការមកដល់ប្រទេសកាណាដារបស់ប្រជាជនកម្ពុជា តាំងពី៣៥ឆ្នាំមកនេះ។

សូមគោរព

- លោកស្រីកាធ្លីន វែល (Kathleen Weil) រដ្ឋមន្ត្រីក្រសួងអន្តោប្រវេសន៍ លក្ខណៈចម្រុះ និងសមាហរណកម្ម
- លោកឌីមីទ្រីយ៉ូស ជីមប៊ីស (Dimitrios Jim Beis) ទីប្រឹក្សានៅសាលាក្រុងម៉ុងរេអាល់។
- លោកអាឡង់ ដឺស៊ូសា (Alan DeSousa) អភិបាលខណ្ឌសាំងឡូរ៉ង់។
- លោកហ្វ្រង់សេសស្កូ មីល (Francesco Miele) និង លោកអារេហ្វ សាឡឹម (Aref Salem) ទីប្រឹក្សារបស់សាលាក្រុង នៅខណ្ឌសាំងឡូរ៉ង់។
- លោកតំណាងរាស្ត្រ ស្តេផាន ឌីយ៉ុង (Stéphan Dion) លោកអាឡេចហ្សង់ ប៊ូឡឺរី (Alexandre Boulerie) និងលោកអាមីរ ខាឌីរ (Amir Khadir)។
- សហការីទាំងអស់ មិត្តភក្តិទាំងអស់ និង ក្រុមគ្រួសារជាទីស្នេហា។

នៅថ្ងៃ១៧ មេសា ១៩៧៥ ផែនដីបានឈប់វិល សម្រាប់ពួកយើងទៅហើយ។ ជីវិត ក៏លែងរស់រាន សម្រាប់ពួកយើងដែរ ។

ប្រទេសកម្ពុជា... ប្រទេសកម្ពុជាដែលយើងធ្លាប់ស្គាល់ ប្រទេសកម្ពុជាដែលយើងធ្លាប់ស្រឡាញ់ លែងជាប្រទេសកម្ពុជាដូចពីមុនទៀតហើយ។ ជាការពិតណាស់ វាជារឿងកាលពី អតីតកាល ប៉ុន្តែប្រៀបបានដូចជាជារឿងក្នុងពេលបច្ចុប្បន្នដែរ... វាស្ថិតនៅចិត្តរបស់ពួកយើងជានិច្ច។

ពួកយើងបានស្គាល់រួចហើយនូវរបបគួរឲ្យភ័យខ្លាច និងគួរឲ្យរន្ធត់ ក្នុងពេលជិត៤ឆ្នាំ។ ថ្ងៃនេះ ក្នុងពេលនេះ ពួកយើងនៅទីនេះ ចំពោះមុខអ្នកទាំងអស់គ្នា។ សហគមន៍ទាំងមូលនៅទីនេះ យុវជនទាំងអស់ក៏នៅទីនេះដែរ។

ដោយសារតែឥស្សរជនម្នាក់ គឺលោកហ្សាក់ គូតួ (Jacques Couture) រដ្ឋមន្ត្រីក្រសួងអន្តោរប្រវេសន៍ ក្រោមការដឹកនាំរបស់រដ្ឋាភិបាលរបស់លោក រឺណេ ឡេវេស (René Lévesque) ក៏ដូចជា ដោយសារតែរដ្ឋាភិបាលកាណាដាដែរ ទើបអ្នកទាំងអស់បានមកដល់ទីនេះ កាលពី៣៥ឆ្នាំមុន។ យើងខ្ញុំពិតជាជំពាក់គុណលោក ហ្សាក់ គូតួ និង រដ្ឋាភិបាលកាណាដា ជារៀងរហូត។ ទឹកដីកាណាដានេះហើយ ទឹកដីកេបិចនេះហើយ ទឹកកដីនេះម៉ុងរេអាល់នេះហើយ ដែលពួកយើងចាត់ទុកដូចជាទឹកដីកំណើតរបស់យើង។

ហើយខ្ញុំសូមថ្លែងអំណរគុណចំពោះអ្វីៗគ្រប់យ៉ាងទាំងនោះ។ តាងនាមឲ្យសហគមន៍ទាំងមូល សូមអរគុណ។

នៅពេលដែលយើងខ្ញុំនិយាយពីការចាប់កំណើតឡើងវិញ គឺយើងនិយាយពី ការកើតឡើងវិញ បន្តិចម្តងៗ។ គឺថា យើងប្រើពេលជាង ៤០ឆ្នាំមកហើយ។ ខ្ញុំសឹងតែមិនជឿទេថាវាយូរបែបនោះ ពីព្រោះថាដោយសារតែការស្តុតចិត្តវាខ្លាក្លានេះបែបនេះ ទើបម្នាក់ៗចេះតែបន្តរំឭកពីហេតុការណ៍នោះ... ។ លោកអ្នកដឹងស្រាប់ហើយថា ភាពស្ងប់ស្ងៀមស្ងាត់នេះ ពិតជាលាន់ឮឡើងហឹងត្រចៀក គឺហឹងពេញត្រចៀកតែម្តង។

លុះចំណេរតមក មជ្ឈមណ្ឌលខេមរានេះ ក៏បានចាប់បដិសន្ធិឡើង តែមិនមែនកើតឡើងដោយខ្លួនឯកឯងនោះទេ។ នៅអំឡុងទស្សវត្សទី៨០ នៅពេលដែលជនភៀសខ្លួន បានមកដល់ដំបូងៗ មានស្ត្រីដ៏ឆ្នើម មានបុរសដ៏ឆ្នើម មានសមាគមកម្ពុជាដ៏ឆ្នើម ដែលបានឆ្លើមនិងបន្សល់ទុកនូវមជ្ឈមណ្ឌលខេមរា ដូចយើងឃើញក្នុងពេលនេះ។ ក្នុងថ្ងៃនេះ យើងខ្ញុំសូមធ្វើការកិច្ចចំពោះរៀមច្បងយើងទាំងអស់នោះ។

នៅមជ្ឈមណ្ឌលខេមរា យើងខ្ញុំប្រមូលបានសាក្សីដែលនៅរស់រានមានជីវិត និងកូនៗរបស់អ្នកដែលសល់ពីស្លាប់បានចំនួនប្រមាណជាង៦០នាក់ តាមរយៈគម្រោង “រឿងរ៉ាវជីវិត” ដោយសហការជាមួយសាកលវិទ្យាល័យកុងកកឌីយ៉ា (Université Concordia)។ ហើយ យើងខ្ញុំក៏បានដឹងថាអ្នកទាំងនោះចេះនិយាយហើយ។ ពួកគាត់បានប្រាប់យើងថា ៖ “ពេលនេះយើងអាចនិយាយបានហើយ។ យើងអាចធ្វើបាន។ សូមស្តាប់ពួកខ្ញុំនិយាយចុះ”។

អ្នកទាំងអស់គ្នាឃើញទេ ខណៈដែលជនតក់ស្តុតចេញផុតពីអំពើឃោរឃៅ គឺថាទីនេះ ខ្ញុំមិនត្រឹមតែសំដៅតែមិត្តភ្ងាន់ដារ មិត្តជ្វីហ្វ មិត្តអារមេនីរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែខ្ញុំក៏លើកឡើងផងដែរពីអ្នកទាំងឡាយណាដែលទទួលរងការឈឺចាប់នៅលើភពផែនដីនេះ។ នៅពេលដែលអ្នកទាំងនោះនិយាយ គ្មាននរណាម្នាក់ស្តាប់នោះទេ គ្មានសោះតែម្តង។ តើគេត្រូវរង់ចាំ៤០ឆ្នាំសិនទើប ទើបនាំគ្នាធ្វើអ្វីមួយមែនទេ ? ទេ ខ្ញុំសង្ឃឹមថាមិនមិនដូច្នោះទេ យើងខ្ញុំសង្ឃឹមថាមិនយ៉ាងនោះឡើយ។

ពួកយើងមានមហិច្ឆិតាយ៉ាងធំចំពោះអនាគតរបស់មជ្ឈមណ្ឌលខេមរា។ មហិច្ឆិតាទាំងនេះមិនមែនសម្រាប់តែសហគមន៍កម្ពុជាប៉ុណ្ណោះទេ... អ្នកទាំងអស់គ្នាឃើញទេ រឿងរ៉ាវផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗក្នុងសហគមន៍ដ៏តូចមួយ ត្រូវបានកត់ត្រាក្នុងប្រវត្តិសាស្ត្រដ៏ធំធេងរបស់ប្រទេសកាណាដា របស់ទីក្រុងគេបិច និងរបស់ទីក្រុងម៉ុងរេអាល់ រួចទៅហើយ។ យើងទាំងអស់គ្នារួមគ្នាជាមិត្តរវាងគ្នាទៅវិញទៅមក ទាំងនៅទីនេះ ទាំងនៅនៅទីផ្សេងទៀត។ សព្វថ្ងៃនេះ យើងកាន់តែវេញគ្នាជាឆ្អុងមួយ ដោយសារតែព្រឹត្តិការណ៍ថ្មីៗដែលកើតឡើងនៅជុំវិញពិភពលោក។

ខ្ញុំសូមបញ្ចប់សង្គតថានេះ ដោយបញ្ចូលពាក្យមួយឃ្លារបស់អ្នកដឹកនាំខ្សែភាពយន្តខ្មែរសញ្ជាតិ បារាំងមួយរូប គឺលោក រិទ្ធ ប៉ាន់។ ខ្ញុំយល់ថាពាក្យមួយឃ្លានេះសង្ខេបយ៉ាងខ្លីនូវក្តីសង្ឃឹមរបស់យើង គឺថា៖ សេចក្តីស្លាប់ ទារុណកម្ម ការឈឺចាប់ មិនអាចបំផ្លាញជីវិត ការចងចាំចំពោះបុព្វបុរសយើង ចំពោះឪពុកម្តាយយើងដែលបានចែកឋានទៅហើយនោះបានឡើយ។

ខ្ញុំសូមអានជូនអ្នកទាំងអស់គ្នានូវសម្រង់ឃ្លានោះ ៖ □ខ្ញុំមិនបានអរគុណដល់ម្តាយខ្ញុំ ចំពោះអ្វីដែលគាត់បានធ្វើ សម្រាប់ជើងរបស់ខ្ញុំ សម្រាប់គ្រប់យ៉ាង ចំពោះជីវិតខ្ញុំនេះ។ គាត់បានហៅ ខ្ញុំពីចម្ងាយ។ ហើយគាត់បានស្រែកប្រាប់ខ្ញុំយ៉ាងទាំងនេះ ៖ □រិទ្ធ នៅក្នុង ឆាកជីវិត កូនត្រូវតែបោះជំហានទៅមុខ ទោះបីជាមានឧបសគ្គអ្វីក៏ដោយ កូនត្រូវតែដើរទៅមុខ។ នោះគឺជាបញ្ជា□។ ខ្ញុំលែងបានឃើញគាត់ជារៀងរហូត□។ ដូច្នេះ នៅពេលនេះ យើងត្រូវបោះជំហានទៅមុខ។ ពួកយើងដើរទៅមុខរួមគ្នា ដើម្បីឲ្យបុព្វបុរសយើងនៅតែស្ថិតស្ថេរជារៀងរហូត។ ប៉ុន្តែយើងក៏គិតដល់កូនចៅយើងជំនាន់ក្រោយ ដែលនឹងត្រូវកសាងសង្គមនេះ។ ដូចសម្តីរបស់អ្នក រួចផុតពីសេចក្តីស្លាប់នៅជំរំពិឃាដ អៅស្វីត (Auschwitz) ដែលមានប្រសាសន៍ថា □សូមកុំធ្វើឲ្យអតីតកាលក្លាយទៅជាអនាគតកាលដល់កូនចៅជំនាន់ក្រោយរបស់យើង□។

សូមអរគុណ